22110535

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A1 – STANDARD LEVEL – PAPER 1**
**KHMER A1 – NIVEAU MOYEN – ÉPREUVE 1**
**KHMER A1 – NIVEL MEDIO – PRUEBA 1**

Wednesday 11 May 2011 (morning)
Mercredi 11 mai 2011 (matin)
Miércoles 11 de mayo de 2011 (mañana)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a commentary on one passage only. It is not compulsory for you to respond directly to the guiding questions provided. However, you may use them if you wish.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire sur un seul des passages. Le commentaire ne doit pas nécessairement répondre aux questions d'orientation fournies. Vous pouvez toutefois les utiliser si vous le désirez.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario sobre un solo fragmento. No es obligatorio responder directamente a las preguntas que se ofrecen a modo de guía. Sin embargo, puede usarlas si lo desea.


© International Baccalaureate Organization 2011

https://xtremepape.rs/

*សូមអ្នកសរសេរអត្ថាធិប្បាយទៅលើអត្ថបទតែ**មួយ** ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ*

**១.**

**មេឃគ្មានផ្កាយ**

វិរាជធ្វើមុខអេះអុញ គេមិនចង់អោយមុន្នីមើលងាយឡើយ តែកាលៈទេសៈបែបនេះហើយ អ្នកណាឆ្លាត អ្នកនោះឈ្នះ យកពិន្ទុអោយបានសិន ព្រោះអ្នកចេះដប់មិនស្មើអ្នកប្រសប់មួយ ហើយអ្នកដែលរៀនបានថ្នាក់ខ្ពស់ មិនប្រាកដថាពូកែជាងអ្នកដែលរៀនបានថ្នាក់ទាបតែមានបទពិសោធក្នុងការងារប្រចាំថ្ងៃដែរ ។ នាឡិការោទិ៍ឡើង វិរាជធ្វើចប់ល្មម គេញញឹមស្រស់ ចំណែកសិស្សខ្លះមុខស្អុយ ព្រោះធ្វើមិនចេញ ។ វិរាជកាន់ប៊ិច និងសៀវភៅ ចេញមកខាងក្រៅថ្នាក់ មើលឆ្វេងស្តាំរកមុន្នី តែមិនឃើញ ។ ភិរុណដើរមកពីក្រោយ ទះស្មាវិរាជៈ

— រកមើលមុន្នីមែនទេ? តោះគ្នាឃ្លានណាស់ ទៅរកញ៉ាំអីនៅកង់ទីនសាលាល្អជាង! ព្រឹកមិញប្រញាប់ពេក មិនបានញ៉ាំអីទ្រាប់ពោះផង! បន្តិចទៀតត្រូវប្រឡងទៀតហើយ ។

វិរាជញាក់ស្មាបន្តិច តបបែបហីៈ

— រឿងអីដែលយើងត្រូវរកមើលនាងនោះ!

វិរាជដើរចេញយ៉ាងលឿន ភិរុណដើរតាមក្រោយលួចញញឹមហួសចិត្ត ។

នៅតុអាហារ ភិរុណ វិរាជកំពុងញ៉ាំបបរ ឯណារ៉េតកាន់ទឹកក្រូចបីកំប៉ុងដើរមកអង្គុយជុំមិត្តមុខស្អុយប៉ែៈ

— សិយណាស់! យប់មិញ មិនបានមើលមេរៀន ឥឡូវប្រហែលជាប្រឡងធ្លាក់ហើយ!

ភិរុណអស់សំណើច ដាក់ស្លាបព្រាបបរចុះៈ

— មិនមែនរឿងសិយ រឿងហេងទេរ៉េត! មកពីឯងខ្ជិលមើលមេរៀនគឺបែបនេះហើយ! ដូចគ្នាប្រាប់អញ្ចឹង ថាគ្មានអ្វីប្រសើរជាងពឹងលើខ្លួនឯងនោះទេ ។ ពេលធម្មតា គ្នាអាចជួយឯងបាន តែពេលសំខាន់ៗបែបនេះ គឺគ្នាជួយមិនបានឡើយ!

— គ្នាដឹងហើយ! កុំជាន់បន្ថែមបានទេ! តែទោះប្រឡងមិនជាប់ ក៏គ្នាមិនអត់ការងារធ្វើអ្វីដែរ ព្រោះក្រុមហ៊ុនប៉ាគ្នាមានច្រើនគគោក ។

— ឯងគិតបែបនេះក៏បាន! តែបើឯងធ្វើជាអ្នកដឹកនាំគេ ហើយមិនចេះអ្វីសោះនោះ អ្នកនៅក្រោមបង្គាប់នឹងរិះគន់មិនខាន ។ យើងជាម្ចាស់ត្រូវតែស្គាល់ និងយល់ដឹងពីអ្វីដែលជារបស់យើង ។ សុខចិត្តអោយគេគោរពប្រសើរជាងអោយគេខ្លាចព្រោះតែយើងមានអំណាចជាម្ចាស់ ។ គេខ្លាចតែចំពោះមុខ តែនៅពីក្រោយខ្នងគេស្អប់ ។

ណារ៉េតប្រែទឹកមុខទ្រឹងគិត ព្រោះគេភ្លេចគិតពីចំណុចនេះ ។ ដល់ពេលភិរុណនិយាយ ធ្វើអោយគេភ្ញាក់ខ្លួនតែម្តង ។ ចំណែកវិរាជ ទោះគេមិនមាត់មិនក តែអ្នកកំពុងរិះគិតដែរ ថាពេលវេលាកន្លងអ្នកចំណាយពេលវេលាដោយឥតប្រយោជន៍ នឹកដល់ពាក្យដែលបងប្រុសនិយាយ និងភិរុណដាស់តឿនគឺត្រឹមត្រូវបំផុត ។ ពេលវេលាមិនអាចត្រឡប់ក្រោយឡើយ តែយើងក៏មិនត្រូវគិតអ្វីដែលកន្លងទៅរួចហើយនោះដែរ ព្រោះពេលវេលាខាងមុខកំពុងរង់ចាំយើង ធ្វើជាមនុស្សត្រូវសម្លឹងផ្លូវនៅខាងមុខជានិច្ច កុំដើរត្រឡប់ក្រោយអោយសោះ ។

ដកស្រង់ពីរឿង ភ្លើងស្នេហ៍យុវវ័យ វគ្គទី៣ "មេឃគ្មានផ្កាយ"
និពន្ធដោយ អ្នកស្រី ម៉ៅ សំណាង បោះពុម្ព ឆ្នាំ ២០០៨



https://xtremepape.rs/

– តើអ្នកអាចនិយាយបានយ៉ាងដូចម្ដេចចំពោះវិធីសាស្ត្រនៃការប្រើភាសាដែលអ្នកនិពន្ធបានប្រើដើម្បីបង្ហាញតួអង្គ នៅក្នុងអត្ថបទដកស្រង់នេះ?

— ចូរអ្នកធ្វើការអត្ថាធិប្បាយទៅលើការប្រើភាសារបស់អ្នកនិពន្ធដើម្បីបង្ហាញអំពីគំនិតចំបងរបស់ អត្ថបទនេះ ។

— ចូររៀបរាប់អំពីបរិយាកាសក្នុង អត្ថបទនេះ ។ តើបរិយាកាសនោះ ត្រូវបាន បង្កើតឡើងយ៉ាងដូចម្ដេច?

— ចូរអ្នកធ្វើការអត្ថាធិប្បាយទៅលើ វិធីតែងសំខាន់ៗ ដែលអ្នកនិពន្ធបានប្រើប្រាស់នៅក្នុង អត្ថបទដកស្រង់នេះ ។



https://xtremepape.rs/

២.

## គុណវិបត្តិពីគ្រោះអវិជ្ជា

មិនចេះវិជ្ជាដូចមនុស្សខ្វាក់
មិនឃើញគ្រោះថ្នាក់ចំពោះមុខ
ជាឈើខ្ញូតស៊ីងាយបាក់ពុក
ជំងឺទូរទុក្ខរីងរៃក្រៃ ។
មិនចេះវិជ្ជាខ្មាស់គេឯង
ក្នុងខ្លួនចំបែងរាល់យប់ថ្ងៃ
ស្មារតីងាយខ្លាចងាយឆាប់ភ័យ
ខ្វះការឈ្លាសវៃពិចារណា ។
មិនចេះវិជ្ជាមិនសមរម្យ
អាប់ដល់សង្គមដល់គ្រួសារ
គ្មានសិរីសួស្តីគ្មានប្រាជ្ញា
ស្រួលងាយក្នុងការគេបោកបាន ។
មិនចេះវិជ្ជាជីវភាពស្មុគ្រ
ស្មាញគេចាក់រុកងាយឈឺប្រាណ
ប្រកបការងារទាំងព្រាវស្មាន
ទៅមុខដូចឡានដាច់ចង្កូត ។
មិនចេះវិជ្ជាជាវិបត្តិ
ងងឹតសូន្យស្ងាត់រៀងរហូត
អវិជ្ជាគឺល្ងង់មិនរៀនសូត្រ
ដូចទ្រមិនក្លូតពិរោះអី?

កំនាព្យ បទពាក្យ៧ “គុណវិបត្តិពីគ្រោះអវិជ្ជា”
និពន្ធដោយ លោក ម៉ៅ អាយុទ្ធ ឆ្នាំ ១៩៨៥

— ចូរអ្នកធ្វើការអត្ថាធិប្បាយទៅលើការប្រើភាសារបស់អ្នកនិពន្ធក្នុងការបង្ហាញអំពីគំនិតចំបងរបស់ អត្ថបទកាព្យនេះ ។

— នៅក្នុងអត្ថបទកាព្យនេះតើអ្នកអាចនិយាយបានយ៉ាងដូចម្តេចចំពោះវិធីសាស្ត្រដែលអ្នកនិពន្ធបានប្រើដើម្បី ទាញចេញនូវការ ឆ្លើយតបពីអ្នកអាន?

— តើ រចនាសម្ពន្ធ ត្រូវបានប្រើយ៉ាងដូចម្តេច និង ប្រើក្នុងគោលបំនងអ្វី នៅក្នុងអត្ថបទកាព្យនេះ?



https://xtremepape.rs/